**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតជូនពរ
# សម្ដេចក្រឡាហោម ស ខេង
# ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

*សម្ដេចក្រឡាហោម ជាទីស្រឡាញ់រាប់អាន!*

នាឱកាសដ៏មហានក្ខត្តឫក្សប្រសើរថ្លៃថ្លា និងប្រកបដោយសេចក្ដីសោមនស្សរីករាយ នៃពិធីចម្រើនជន្មាយុរបស់សម្ដេចក្រឡាហោម ខ្ញុំ និងភរិយាសូមសម្ដែងនូវមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅ ព្រមជាមួយនូវអំណរសាទរ និងពរជ័យសិរីមង្គលដ៏មហាប្រសើរជូនចំពោះសម្ដេច សូមបានប្រកបដោយសុខភាពល្អ បរិបូរណ៍ កាយពលមាំមួន បញ្ញាញាណភ្លឺថ្លាវាងវៃ និងជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏សិរីមង្គលនេះផងដែរ ខ្ញុំសូមសម្ដែងនូវការកោតសរសើរយ៉ាងក្រៃលែងចំពោះការខិតខំប្រឹងប្រែងក្នុងបុព្វហេតុបម្រើជាតិមាតុភូមិនិងការពារ ថែរក្សាសន្តិភាព ស្ថេរភាពសង្គម ពង្រឹងនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងគោរពសិទ្ធិមនុស្ស ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ការពារសន្តិសុខនិងសុវត្ថិភាពសង្គមជាតិទាំងមូល។

ជាថ្មីម្ដងទៀត ខ្ញុំ និងភរិយា សូមបួងសួងវត្ថុស័ក្ដិសិទ្ធិទាំងឡាយក្នុងលោក និងទេវតាថែរក្សាទឹកដី សូមជួយប្រោះព្រំសព្ទសាធុការពរ សិរីសួស្ដី ជ័យមង្គល វិបុលសុខ បវរ មហាប្រសើរគ្រប់ប្រការជូនចំពោះសម្ដេចក្រឡាហោម និងលោកជំទាវ បុត្រា បុត្រី ចៅៗជាទីស្រលាញ់ សូមបានប្រកបដោយពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្ដេចក្រឡាហោម** ទទួលការស្រលាញ់រាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ៕

ថ្ងៃអាទិត្យ ៤កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៤
**ប្រធានក្រុមឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**